ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កែបថ្មី

សម្រាប់រយៈពេល០៣ឆ្នាំ (ខែកុម្ភៈ ឆ្នាំ២០២២-ខែធ្នូ ឆ្នាំ២០២៤)

| | |
|---|---|
| សហគមន៍នេសាទ | ៖ កែបថ្មី |
| ភូមិ | ៖ ភូមិកែបថ្មី |
| ឃុំ | ៖ បឹងទូក |
| ស្រុក | ៖ ទឹកឈូក |
| ខេត្ត | ៖ កំពត |

ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១

# មាតិកា

**១.ស្ថានភាពទូទៅ** ........ ១

**២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម** ........ ១

ក.ប្រជាពលរដ្ឋ ........ ១

ខ.មុខរបរ ........ ២

**៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍** ........ ៣

ក.ទីតាំង ........ ៣

ខ.ដែននេសាទ ........ ៣

គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស ........ ៣

ឃ. ធនធានជលផល ........ ៣

១.ប្រភេទត្រី ........ ៤

២.ប្រភេទវារីសត្វ ........ ៤

៣.ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិសមុទ្រ ........ ៤

**៤.ការធ្វើនេសាទ** ........ ៤

ក.អ្នកនេសាទ ........ ៤

ខ.ឧបករណ៍នេសាទ ........ ៤

គ.ប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ ........ ៦

**៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍** ........ ៦

ក.ទស្សនៈវិស័យ ........ ៦

ខ.គោលបំណង ........ ៦

គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ........ ៧

គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ ........ ៧

គ.២.ផែនការចុះល្បាត ........ ៧

គ.៣.ផែនការកែលំអដែននេសាទ ........ ៨

គ.៤.ផែនការរៀបចំកន្លែងអភិរក្ស ........ ៩

គ.៥.ផែនការគ្រប់គ្រងព្រៃកោងកាង ........ ១០

គ.៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម ........ ១១

គ.៧.ផែនការអភិវឌ្ឍន៍ធនាគារក្តាមសេះ ........ ១២

គ.៨.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ ........ ១៣

គ.៩.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ........ ១៤

គ.១០.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ ........ ១៤

គ.១១.ផែនការបង្កើតស្នាក់ការ និងបណ្ណាល័យសហគមន៍នេសាទ....................................................១៥
គ.១២.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍............................................................១៥

ឃ.យុទ្ធសាស្រ្ត ....................................................................................................................១៦

**៦.ឧបសម្ពន្ធ**

ឧបសម្ពន្ធ ៖តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឆ្នាំ២០២២-២០២៤.............................១៧
តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទក្នុងរយៈពេល០៣ឆ្នាំ២០២២-២០២៤................២១

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កែបថ្មី

## ១.ស្ថានភាពទូទៅ

នៅឆ្នាំ២០០០រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងវិស័យជលផល ដើម្បីឱ្យសមស្របជាមួយគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការដែលមានក្នុងជាយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយផ្ដោតលើការកាត់បន្ថយភាពក្រីក្រតាមរយៈការផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋដែលរស់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងសមធម៌តាមបែបសហគមន៍នេសាទក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើឱ្យធនធានជលផលប្រសើរឡើងនៅមូលដ្ឋានរបស់ខ្លួន។ ភូមិកែបថ្មី ត្រូវបានរៀបចំសហគមន៍នេសាទដោយមានការចូលរួមយ៉ាងកុះករពីប្រជាពលរដ្ឋមូលដ្ឋាន និងបានទទួលការគាំទ្រថវិកាពីរដ្ឋបាលជលផល និងមានកិច្ចសហការពីអាជ្ញាធរដែនដី។ ដូចនេះ សហគមន៍នេសាទកែបថ្មីត្រូវបានបង្កើតឡើងដោយមហាសន្និបាតលើកដំបូងនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៥ ដោយបានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រកាសទទួលស្គាល់នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ និងបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍លើកទី១ដែលបានអនុវត្តពីខែមីនា ឆ្នាំ២០១៧ ដល់ ២០២០ ហើយបានរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍លើកទី២ដែលនឹងអនុវត្តចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ ដល់ ខែធ្នូ ឆ្នាំ២០២៤។

គណៈកម្មការសហគមន៍នេសាទ ត្រូវបានបោះឆ្នោតដែលមានសមាជិកគណៈកម្មការសហគមន៍នេសាទមានចំនួន០៧នាក់ ក្នុងនោះស្ត្រីពុំមាន ព្រមទាំងបានអនុវត្តតួនាទី និងភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀងកន្លែងនេសាទ និងផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍។ ទន្ទឹមនឹងនេះ គណៈកម្មការសហគមន៍នេសាទបានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្ដុះបណ្ដាល សិក្ខាសាលា ប្រជុំការងារ ទស្សនៈកិច្ចសិក្សា និងរៀនសូត្រតាមឯកសារផ្សេងៗ។

គណៈកម្មការសហគមន៍នេសាទកែបថ្មីបានរៀបចំសកម្មភាពសំខាន់ៗ ដើម្បីឱ្យសហគមន៍នេសាទមានផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍សម្រាប់អនុវត្ត និងបង្កលក្ខណៈឱ្យសហគមន៍នេសាទ អាចស្វែងរកថវិកាអនុវត្តការងារសកម្មភាពរបស់ខ្លួន ក្នុងការជួយដល់ការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទសហគមន៍ ព្រមទាំងប្រជាពលរដ្ឋមូលដ្ឋានទទួលបានផលប្រយោជន៍ពីការប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរ។

## ២.អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក.ប្រជាពលរដ្ឋ

នៅពេលបច្ចុប្បន្ន ក្នុងឃុំបឹងទូកមានចំនួន០២ភូមិគឺ ភូមិកែបថ្មី និងភូមិទទឹងថ្ងៃ ដោយឡែកសហគមន៍នេសាទកែបថ្មីគ្របដណ្ដប់តែមួយភូមិ គឺភូមិកែបថ្មីដែលមានប្រជាពលរដ្ឋសរុបចំនួន៤៧៥គ្រួសារ ហើយគ្រួសារដែលមានស្ត្រីជាមេគ្រួសារមានចំនួន១០៥គ្រួសារដែលស្មើនឹងមនុស្សសរុបចំនួន២៣២៣នាក់ ក្នុងស្ត្រីមានចំនួន ១២០០នាក់។ ដោយឡែក សហគមន៍នេសាទកែបថ្មីមានសមាជិកសរុបចំនួន១៤៧នាក់ក្នុងនោះស្ត្រីចំនួន៨៩នាក់ ។ សហគមន៍នេសាទកែបថ្មីស្ថានភាពដូចជា៖

- ផ្អែកតាមការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅភូមិកែបថ្មីបានបង្ហាញថា គ្រួសារដែលស្ថិតក្នុងស្ថានភាពក្រីក្រ១មានចំនួន៣៧គ្រួសារ ក្នុងនោះស្ត្រីចំនួន០៨គ្រួសារ និងស្ថានភាពក្រីក្រ២មានចំនួន២៦គ្រួសារ ក្នុងនោះស្ត្រីចំនួន០៦គ្រួសារ ដែលសរុបចំនួន៦៣គ្រួសារ
- ស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមានចំនួន៣២នាក់

- បុរសពោះម៉ាយក្នុងសហគមន៍នេសាទមានចំនួន១១នាក់
- ជនពិការក្នុងសហគមន៍នេសាទមានចំនួន១៤នាក់ ក្នុងនោះស្ត្រីមានចំនួន០៤នាក់
- កុមារកំព្រាក្នុងសហគមន៍នេសាទមានចំនួន០៥នាក់ ក្នុងនោះកុមារីមានចំនួន០២នាក់
- ចាស់ជរាក្នុងសហគមន៍នេសាទមានចំនួន៣០នាក់ ក្នុងនោះស្ត្រីមានចំនួន១២នាក់
- អ្នកមានជម្ងឺរាំរ៉ៃក្នុងសហគមន៍នេសាទមានចំនួន១០នាក់ ក្នុងនោះស្ត្រីមានចំនួន០៧នាក់
- គ្រួសារដែលកើតមេរោគអេដ៏មានចំនួន១៤នាក់ ក្នុងនោះស្ត្រីមានចំនួន១១នាក់។
- សាលារៀនបឋមសិក្សាសរុប០១មានចំនួន០២ខ្នងដែលមាន០៦បន្ទប់ ហើយមានសិស្សសរុបចំនួន២២១នាក់ ក្នុងនោះកុមារីមានចំនួន១០៤នាក់។
- តាមរបាយការណ៍របស់ក្រុមប្រឹក្សាឃុំបឹងទូក នៅក្នុងសហគមន៍នេសាទនេះបានបង្ហាញថា មានមនុស្សចំនួន១៥នាក់ដែលមិនចេះអក្សរក្នុងនោះស្ត្រីមានចំនួន០៩នាក់។

**ខ.សេដ្ឋកិច្ចសង្គម**

តាមរបាយការណ៍ និងឯកសារព័ត៌មានឃុំឆ្នាំ២០២១បានបញ្ជាក់ថា នៅក្នុងសហគមន៍នេសាទកែបថ្មី មានប្រជាពលរដ្ឋភាគច្រើនពឹងផ្អែកលើការធ្វើនេសាទ ចិញ្ចឹមសត្វ ធ្វើស្រែ កម្មករ និងលក់ដូរ។ ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទជាសកម្មភាពចំបង ដែលអាចជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេសបានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមក រដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន ។

ពេលបច្ចុប្បន្ន នៅក្នុងសហគមន៍នេសាទកែបថ្មី ប្រជាពលរដ្ឋមានស្ថានភាពនៃការចិញ្ចឹមជីវិត និងមុខរបរសំខាន់ៗរួមមាន៖

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | សំគាល់ |
|---|---|---|---|
| ១ | អ្នកដែលមានមុខរបរពឹងផ្អែកលើការនេសាទ | ២០០ | មុខរបរចំបង |
| ២ | អ្នកដែលធ្វើនេសាទ ធ្វើស្រែ និងអ្នកចិញ្ចឹមសត្វ | ២៧៥ | |
| ៣ | អ្នកកែច្នៃផលនេសាទទូទៅ | ១៨០ | |
| ៤ | អ្នកកែច្នៃបង្គាក្រៀម | ២៥ | |
| ៥ | អ្នកចំហុយត្រីកាម៉ុង | ០៦ | |
| ៦ | អ្នកកែច្នៃផ្អកចាវ | ០៥ | |
| ៧ | អ្នកកែច្នៃក្តាមសេះ | ៣៤ | បកយកសាច់ |
| ៨ | អ្នកកែច្នៃត្រីប្រឡាក់ | ១៥ | |
| ៩ | កម្មករ | ២៧១ | |
| ១០ | ជួសជុល និងជាងធ្វើទូក | ០៧ | |
| ១១ | អ្នកលក់ដូរ | ១២០ | |
| ១២ | ជាងធ្វើម៉ាស៊ីនកាណូត | ០៥ | |

## ៣.កន្លែងនេសាទ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក.ទីតាំង

សហគមន៍នេសាទកែបថ្មី មានទីតាំងស្ថិតក្នុងភូមិកែបថ្មីដែលជាដែននេសាទសាធារណៈរបស់រដ្ឋ ហើយដែននេសាទនៅជាប់សមុទ្រដែលស្ថិតក្នុងឃុំបឹងទូក ស្រុកទឹកឈូក ខេត្តកំពត។ សហគមន៍នេសាទកែបថ្មីត្រូវបានកំណត់និយាមកាដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ដូចនេះ សហគមន៍នេសាទកែបថ្មីមានព្រំប្រទល់ជាប់នឹង៖

- ខាងជើងជាប់នឹងដីស្រែប្រជាពលរដ្ឋភូមិកែបថ្មី
- ខាងត្បូងជាប់នឹងឆ្នេរសមុទ្រ
- ខាងកើតជាប់នឹងសហគមន៍នេសាទទទឹងថ្ងៃ
- ខាងលិចជាប់នឹងព្រែករលួស។

### ខ.ដែននេសាទ

កន្លែងនេសាទសហគមន៍នេសាទកែបថ្មី មានវិសាលភាពនៅលើដែននេសាទសមុទ្រដែលមានកន្លែងនេសាទទំហំ៦៨៣ហិកតា ហើយមានដែននេសាទតំបន់ឆ្នេរ និងព្រែកដូចជា៖

| ល.រ | ឈ្មោះព្រែក | ទំហំ | ការនេសាទ |
|---|---|---|---|
| ១ | ព្រែកជីក | ១២០០ម x ២៥ម | ពេញមួយឆ្នាំ |
| ២ | ព្រែកលោកតាដោក | ២០ម x ១៥ម | ពេញមួយឆ្នាំ |
| ៣ | ព្រែកខ្សៀ | ១៦០០ម x ១៥ម | ពេញមួយឆ្នាំ |

### គ.តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

សហគមន៍នេសាទកែបថ្មី បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន០២កន្លែងគឺ ព្រៃកោងកាងមួយកន្លែងដែលមានទំហំ៨០ហិកតា និងកន្លែងអភិរក្សអាវតាប៊ូដែលមានទំហំ០៥ហិកតា។ ដូចនេះ កន្លែងអភិរក្សទាំងនេះត្រូវបានធ្វើការគ្រប់គ្រងដោយសមាជិកសហគមន៍នេសាទ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះកន្លែងអភិរក្ស | ទំហំជាហិកតា | ការអភិរក្ស |
|---|---|---|---|
| ១ | កន្លែងអភិរក្សព្រៃកោងកាង | ៨០ | ការអភិរក្សធនធានជលផល |
| ២ | អាវតាប៊ូ | ០៥ | អភិរក្សស្មៅ ផ្កាថ្ម និងត្រីមេពូជ |

### ឃ.ធនធានជលផល

នៅក្នុងប្រទេសកម្ពុជា ធនធានជលផលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសន្តិសុខស្បៀង ដោយឡែកត្រីអាចផ្តល់ជាអាហារដល់ការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋប្រចាំថ្ងៃ។ តាមការបង្ហាញពីគណៈកម្មការ និងសមាជិកសហគមន៍នេសាទកែបថ្មី បានឱ្យដឹងថា ពេលបច្ចុប្បន្ននេះ ធនធានជលផលក្នុងសមុទ្រមិនមានការកើនឡើងទេ

ដោយសារមានការប្រែប្រួលអាកាសធាតុជា ពិសេស ការចាក់ដីលុបលើកន្លែងអភិរក្សត្រីកន្លាំងរបស់សហគមន៍នេសាទកែបថ្មី។ ផ្អែកតាមការអង្កេតរបស់ក្រុមការងារ និងសមាជិកសហគមន៍លើធនធានជលផលក្នុងសហគមន៍នេសាទកែបថ្មីមានដូចជា៖

**ឃ.១.ប្រភេទត្រីសមុទ្រ:**

ក្នុងសហគមន៍នេសាទកែបថ្មីមានប្រភេទត្រីដូចជា៖ ត្រីឆ្កង់ ត្រីក្បក ត្រីប្រកុង ត្រីអាំងកីយ ត្រីចង្កោមបី ត្រីដំឡូង ត្រីប្លាធូ ត្រីក្តចិន ត្រីស្លុងក្រហម ត្រីផ្ទោង ត្រីត្រសក់ ត្រីឆ្លាម ត្រីការ៉ាវ ត្រីប្រម៉ា ត្រីកិ ត្រីកន្ទង ត្រីកាម៉ុង ត្រីក្បាលឡាន ត្រីអណ្តែងប៉ុយ ត្រីកន្តាំង ត្រីកន្ទុយរឹង ត្រីកាបាស ត្រីបបែល ត្រីឆ្លាត ត្រីក្អុក ត្រីបាលង្គ ត្រីកាឡាំង ត្រីអង្រែ ត្រីគូន ត្រីសេក ត្រីតក់កែ ត្រីផ្ទក់សមុទ្រ ត្រីសេះ។ល។

**ឃ.២.ប្រភេទវារីសត្វសមុទ្រ:**

ក្នុងសហគមន៍នេសាទកែបថ្មីនេះ មានប្រភេទវារីសត្វដូចជា៖ បង្កង បង្គា ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ មឹកគ្រែងឈាម ងាវភក់ ហូល ងាវស បង្កងប៉ាក អណ្តើក កន្ទាយ បាលង្ក័កាស កញ្ជ អន្ទង់ ខ្ចឹង។ល។

**ឃ.៣.ប្រភេទរុក្ខជាតិព្រៃកោងកាង និងវារីរុក្ខជាតិ**

ក្នុងសហគមន៍នេសាទកែបថ្មី មានប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិដូចជា៖ ផ្កាថ្ម ស្មៅសមុទ្រ និងតំបន់ព្រៃកោកាងមានដូចជា៖ ព្រៃកោងកាង ក្រញឹម អម្ពូ អម្ពា ក្របាញ់ញី ក្របាញ់ឈ្មោល ប៊ីង ប្រសាក ដើមបើស ឈើជ័រ ដើមក្លាយ អញ្ចរ ក្រវាញ ទំពារ។ល។

## ៤.ការធ្វើនេសាទ

តាមការសិក្សា និងប្រមូលទិន្នន័យពីក្រុមប្រឹក្សាឃុំ ភូមិ និងគណៈកម្មការ និងសមាជិកសហគមន៍នេសាទកែបថ្មី បានបង្ហាញពីចំនួនអ្នកដែលពាក់ព័ន្ធក្នុងការធ្វើនេសាទលើកន្លែងនេសាទសហគមន៍កែបថ្មី ដូចមានក្នុងតារាងខាងក្រោម៖

**៤.ក.អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន១៤៧ នាក់ ក្នុងនោះស្ត្រីមានចំនួន៨៩នាក់។
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទនៅក្នុងសហគមន៍មានចំនួន៨០នាក់ ក្នុងនោះស្ត្រីមានចំនួន១៤នាក់។
- តាមការប៉ាន់ស្មានអ្នកនេសាទដែលមកពីខាងក្រៅ ហើយមិនមែនជាសមាជិកមានចំនួន១៥០នាក់ ក្នុងនោះស្ត្រីចំនួន៣៧នាក់ ក្នុង០១ឆ្នាំ។

**៤.ខ.ឧបករណ៍នេសាទ**

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍មានដូចជា៖

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទដែលប្រើប្រាស់ក្នុងសហគមន៍

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងត្រីក្បក | ម៉ែត្រ | ៩០ | ពេញមួយឆ្នាំ |
| ២ | មងត្រីថ្កោង | ម៉ែត្រ | ១៥០ | ពេញមួយឆ្នាំ |
| ៣ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ៤ | រនងខ្សែងដាក់មឹក | សំបក | ១០០០ | ពេញមួយឆ្នាំ |
| ៥ | លបក្តាម | លប | ៥០០ | ពីខែ១២ ដល់ ខែ០១ |
| ៦ | មងបង្គា | ម៉ែត្រ | ១៥០ | ពីខែ១២ ដល់ ខែ០១ |
| ៧ | មងក្តាម | ម៉ែត្រ | ១៧៥ | ពីខែ១១ ដល់ ខែ០១ |
| ៨ | សន្ទូចត្រីអន្ទែងប៉ុយ | ផ្លែ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៩ | មងត្រីកន្តាំង | ម៉ែត្រ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |

| ល.រ | ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|---|
| ១ | ទូកម៉ាស៊ីន | ៣៥ | ៧០០-១០០០ | ២៤ ដល់ ៦០ |
| ២ | ទូកចែវ | ០៥ | ៧០-១០០ | |

ឧបករណ៍នេសាទ ទូក និងកាណូតរបស់អ្នកខាងក្នុងសហគមន៍នេសាទតែមិនមែនជាសមាជិក

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងត្រីក្បក | ម៉ែត្រ | ៩០ | ពេញមួយឆ្នាំ |
| ២ | មងត្រីថ្កោង | ម៉ែត្រ | ១៥០ | ពេញមួយឆ្នាំ |
| ៣ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ៤ | រនងខ្សែងដាក់មឹក | សំបក | ១០០០ | ពេញមួយឆ្នាំ |
| ៥ | លបក្តាម | លប | ៥០០ | ពីខែ១២ ដល់ ខែ០១ |
| ៦ | មងបង្គា | ម៉ែត្រ | ១៥០ | ពីខែ១២ ដល់ ខែ០១ |
| ៧ | មងក្តាម | ម៉ែត្រ | ១៧៥ | ពីខែ១១ ដល់ ខែ០១ |
| ៨ | សន្ទូចត្រីអន្ទែងប៉ុយ | ផ្លែ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |
| ៩ | មងត្រីកន្តាំង | ម៉ែត្រ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |

| ល.រ | ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|---|
| ១ | ទូកម៉ាស៊ីន | ៤០ | ៧០០-១០០០ | ២៤ ដល់ ៦០ |

ឧបករណ៍នេសាទ ទូក និងកាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ

| ល.រ | ឧបករណ៍នេសាទ | ឯកតា | ប្រវែង/ទំហំ/ចំនួន | រដូវនេសាទ |
|---|---|---|---|---|
| ១ | មងត្រីក្បក | ម៉ែត្រ | ៩០ | ពេញមួយឆ្នាំ |
| ២ | លបក្តាមសេះ | លប | ២៥០ | ពេញមួយឆ្នាំ |
| ៣ | លបក្តាម | លប | ៥០០ | ពីខែ១២ ដល់ ខែ០១ |
| ៤ | មងបង្គា | ម៉ែត្រ | ១៥០ | ពីខែ១២ ដល់ ខែ០១ |
| ៥ | មងក្តាម | ម៉ែត្រ | ១៧៥ | ពីខែ១១ ដល់ ខែ០១ |
| ៦ | មងត្រីកន្តាំង | ម៉ែត្រ | ១៥០ | ពីខែ០៤ ដល់ ខែ០៧ |

| ល.រ | ប្រភេទទូក កាណូត | ចំនួន(គ្រឿង) | ចំណុះ(គក) | កំលាំងសេះ |
|---|---|---|---|---|
| ១ | ទូកម៉ាស៊ីន | ១៥០ | ៧០០-១០០០ | ២៤ ដល់ ៦០ |

គ.ការប៉ាន់ប្រមាណផលនេសាទចាប់បានប្រចាំឆ្នាំ

| ល.រ | ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជាគក្រ) | | |
|---|---|---|---|---|
| | | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ១ | ត្រីគ្រប់ប្រភេទ | ១២៣ | ១៣៦ | ២៥៩ |
| ២ | បង្គា | ៨៧ | ១១៧ | ២០៤ |
| ៣ | ក្តាម | ៨១ | ៩៨ | ១៧៩ |
| ៤ | មឹក ខ្យង និងគ្រែងឈាម | ៦៩ | ៩៣ | ១៦២ |
| សរុប | | ៣៦០ | ៤៤៤ | ៨០៤ |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក.ទស្សនៈវិស័យ

សហគមន៍នេសាទកែបថ្មី មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ.គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទសមុទ្រជាកន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ក្នុងរដូវទឹកជោរ និងព្រៃកោងកាង និងការគ្រប់គ្រងកន្លែងអភិរក្ស។

- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទតាមរយៈការអភិវឌ្ឍន៍ចំរុះ។
- ដើម្បីឱ្យប្រជាពលរដ្ឋបានយល់ច្បាស់ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

**គ.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

**គ.១.ផែនការប្រើប្រាស់ឧបករណ៍នេសាទ:**

**គោលបំណង**

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍កែបថ្មីគឺ រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែង ចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ រដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងដែននេសាទ ដោយធ្វើយ៉ាងណាមិនឱ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។
ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

**ទីតាំង ឬកន្លែងនេសាទ**

| ល.រ | ឈ្មោះទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | |
|---|---|---|---|---|
| | | | ប្រភេទ | ទំហំ/ប្រវែង |
| ១ | ដែននេសាទផ្សេងៗក្រៅពីតំបន់អភិរក្សរបស់សហគមន៍នេសាទកែបថ្មី | ប្រភេទត្រី | មងបង្គា មងត្រី លបក្តាម ឈិបរុញ សន្ទូចមឹក រនងខ្យង។ល។ | អនុវត្តតាមប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ២០១៥។ |

**សំគាល់:** ត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ៣១៩ ប្រក.កសក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកំណត់ប្រភេទឧបករណ៍ដែលអនុញ្ញាតិឱ្យធ្វើនេសាទក្នុងដែននេសាទសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

**គ.២.ផែនការចុះល្បាត**

ជាទូទៅ ការចុះល្បាតជាភារកិច្ចរបស់គណៈកម្មការ និងសមាជិកសហគមន៍ ប៉ុន្តែការចុះល្បាតនេះគឺផ្អែកលើការជួយឧត្ថម្ភពីដៃគូអភិវឌ្ឍន៍។ កន្លងមក ការចុះល្បាតលើកន្លែងនេសាទសហគមន៍បានអនុវត្តតិចតួចពីព្រោះថា ខ្វះមធ្យោបាយល្បាត។ ដូចនេះ គណៈកម្មការ និងសមាជិកសហគមន៍នេសាទកែបថ្មីបានគ្រោងរៀបចំផែនការល្បាតក្នុងគោលបំណងដូចជា៖

- ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់
- សមាជិកអាចទទួលបានផលនេសាទពីកន្លែងនេសាទសហគមន៍
- គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព។

ផែនការចុះទប់ស្កាត់បទល្មើសជលផល ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| លរ | សកម្មភាព | ប៉ាន់ប្រមាណតម្លៃ(រៀល) | អ្នកចូលរួម | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ១ | ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ៥០០ ០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០២២ | ២០២៤ |
| ២ | រៀបចំមធ្យោបាយ និងសម្ភារៈ<br>• សាំង និងប្រេងបាត<br>• អាវភ្លៀង អាវពោង ពិល មួក<br>• កាតទូរស័ព្ទ អាយកូមទាក់ទង<br>• ម៉ាស៊ីនថត កែវយិត<br>• ទូកម៉ាស៊ីន | ៩ ០០០ ០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល ស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ | ២០២២ | ២០២៤ |
| ៣ | ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ៥០០ ០០០ | ជំនាញជលផល អាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ | ២០២២ | ២០២៤ |
| ៤ | អនុវត្តផែនការ និងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ជលផល និងជំនាញពាក់ព័ន្ធ | ៤ ០០០ ០០០ | គណៈកម្មការ អាជ្ញាធរមូលដ្ឋាន ជំនាញជលផល | ២០២២ | ២០២៤ |

**គ.៣.ផែនការកែលំអរដែននេសាទ**

ផែនការកែលំអដែននេសាទ គឺជាការងារមួយដែលត្រូវទាមទារឱ្យមានការគាំទ្របច្ចេកទេស និងថវិកា ប្រើប្រាស់ពេលវេលាធ្វើការសិក្សាមួយច្បាស់លាស់ ពីព្រោះថាការកែលំអដែននេសាទសហគមន៍នេះ វាពាក់ព័ន្ធជាមួយត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទនៅក្នុងដែននេសាទនោះ។ ដូចនេះផងដែរ ក្នុងកិច្ចប្រជុំរវាងគណៈកម្មការ និងសមាជិកសហគមន៍នេសាទ អាជ្ញាធរមូលដ្ឋាន និងក្រុមសម្របសម្រួលរដ្ឋបាលជលផលថ្នាក់កណ្តាលបានពិនិត្យឃើញថា ដែននេសាទនៅក្នុងសហគមន៍នេសាទកែបថ្មីមានសភាពប្រែប្រួលខ្លះដែលបណ្តាលមកពីកត្តាមនុស្ស និងធម្មជាតិ។

ផែនការកែលំអដែននេសាទក្នុងគោលបំណងដូចជា៖

- បង្កើនផលត្រី និងវារីសត្វគ្រប់ប្រភេទ និងជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ
- ធ្វើឱ្យសំបូរព្រៃលិចទឹកឱ្យនៅក្នុងដែននេសាទសហគមន៍
- ទាក់ទាញភ្ញៀវទេសចរណ៍។

ផែនការកែលំអដែននេសាទ ត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះ ដែននេសាទ | ទំហំ(ហត) | ទំហំដែលត្រូវ កែលំអរ | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ១ | អាវតាប៊ូ | ០៥ | ៣០មx ១០០០ម | ស្តារព្រែកអាវតាប៊ូ | ២០២២ | ២០២៤ |

### គ.៤.ផែនការរៀបចំកន្លែងអភិរក្ស

សហគមន៍នេសាទកែបថ្មី បានសម្រេចបង្កើតកន្លែងអភិរក្សមួយកន្លែងដែលមានទំហំប្រហែល៥ហិកតា ដែលមានឈ្មោះថា កន្លែងអភិរក្ស**អាវតាប៊ូ** និងកន្លែងអភិរក្សព្រៃកោងកាង និងតំបន់ត្រីមេពូជដែលមានទំហំ៨០ ហិកតា។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទ**កែបថ្មី** ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សនេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងសត្វគ្រប់ប្រភេទ
- ថែរក្សាការពារព្រៃលិចទឹកដែលជាជម្រក ប្រភពចំណីរបស់ត្រី និងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ
- ពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេតរបស់ក្រុមការងារ និងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការ និងសមាជិកសហគមន៍នេសាទនេះបានបញ្ជាក់ថា សហគមន៍នេសាទកែបថ្មីបានសម្រេចបង្កើតកន្លែងអភិរក្សដែលពុំអនុញ្ញាតិទូកនេសាទ ឬកាណូតធ្វើការឆ្លងកាត់ក្នុងកន្លែងអភិរក្សនេះដែលជាកន្លែងសំខាន់បំផុតសម្រាប់ធ្វើការអភិរក្សធនធានជលផលដែលសមាជិកសហគមន៍នេសាទ មានសុច្ឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានជលផល និងជាប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់ប្រជា-ពលរដ្ឋក្នុងសហគមន៍។ ដូចនេះ សហគមន៍នេសាទកែបថ្មីបានសម្រេចបង្កើតកន្លែងអភិរក្សដូចបានបញ្ជាក់ក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះកន្លែងអភិរក្ស | ទំហំជាហិកតា | ការអភិរក្ស |
|---|---|---|---|
| ១ | អាវតាប៊ូ | ០៥ | ការអភិរក្សស្មៅ ផ្កាថ្ម និងត្រីគ្រប់ប្រភេទ |
| ២ | ព្រៃកោងកាង និងតំបន់ត្រីមេពូជ | ៨០ | ត្រីមេពូជ ស្មៅ និងផ្កាថ្ម |

កន្លែងអភិរក្សជាកត្តាចាំបាច់ដែលត្រូវរៀបចំកំណត់ព្រំប្រទល់ បោះបង្គលស៊ីម៉ងព្រំប្រទល់ ធ្វើប៉ាណូផ្សព្វផ្សាយ ក្តាខៀនព័ត៌មាន បិទផ្សាយបទបញ្ញត្តិផ្សេងសម្រាប់កន្លែងអភិរក្ស សាងសង់រោងយាមសម្រាប់ក្រុមល្បាតបំពេញការងារ មធ្យោបាយ និងសម្ភារៈផ្សេងទៀត។

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្សនឹងត្រូវរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | ឈ្មោះទីតាំង | ទំហំ (ហត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|---|
| ១ | កន្លែងអភិរក្សអារ៉ាតាប៊ូ | ០៥ | • ប្រភេទត្រីសំខាន់<br>• ប្រភេទផ្កាថ្ម<br>• ប្រភេទសារាយ<br>• ប្រភេទពពួកល្មូន | • ផ្សព្វផ្សាយ<br>• សិក្សាពីកន្លែងអភិរក្ស<br>• បង្គោលស៊ីម៉ង់១៦ដើម<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | ២០២២ | ២០២៤ |
| ២ | ព្រៃកោងកាង និងតំបន់ត្រីមេពូជ | ៨០ | • ប្រភេទត្រីសំខាន់<br>• ព្រៃកោងកាង<br>• ប្រភេទពពួកល្មូន | • ផ្សព្វផ្សាយ<br>• សិក្សាកន្លែងអភិរក្ស<br>• បង្គោលស៊ីម៉ង់១៦ដើម<br>• ធ្វើប៉ាណូផ្សព្វផ្សាយ<br>• សង់រោងយាម<br>• ចុះល្បាតជាប្រចាំ | ២០២២ | ២០២៤ |

**ឥ.៤.ផែនការគ្រប់គ្រងព្រៃកោងកាង**

ព្រៃកោងកាង បានគ្រប់ដណ្តប់លើដែននេសាទសហគមន៍នេះដែលមានទំហំប្រហែល៨០ហិកតា ដោយបានផ្តល់នូវសក្តានុពល និងសារៈប្រយោជន៍ជាច្រើនដល់ប្រភេទត្រីសត្វល្មូន ប្រភេទសត្វ និងវារីសត្វផ្សេងទៀតសម្រាប់ជាជម្រករស់នៅបង្កកំណើតជាកូន និងជាចំណីផងដែរ។ ដូចនេះ ផែនការគ្រប់គ្រងព្រៃកោងកាងក្នុងគោលបំណងដូចជា៖

- ថែរក្សា ការពារព្រៃកោងកាងឱ្យនៅគង់វង្សយូរអង្វែងដល់ក្មេងជំនាន់ក្រោយ។
- ទុកជាជម្រកត្រី វារីសត្វគ្រប់ប្រភេទ ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ ទប់ស្កាត់ការហូរច្រោះទឹករលក និងជារបាំងខ្យល់។
- បង្កើនទិន្នផលត្រី និងពពួកសត្វមានជីវិតគ្រប់ប្រភេទឱ្យសំបូរឡើង ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។

គណៈកម្មការ និងសមាជិកសហគមន៍នេសាទនេះបានកំណត់ បែងចែកព្រៃកោងកាង កន្លែងអភិរក្ស និងកន្លែងប្រើប្រាស់ព្រៃកោងកាងដោយផ្អែកតាមផែនទីសហគមន៍នេសាទ។ កន្លែងប្រើប្រាស់ព្រៃកោងកាងត្រូវអប់រំណែនាំដល់ប្រជាពលរដ្ឋឱ្យចេះកាប់រំលោះមែកដែលធ្វើយ៉ាងណាមិនឱ្យងាប់ដើម ដើម្បីយកមកប្រើប្រាស់ជាអុសចំអិនអាហារ។

ផែនការគ្រប់គ្រងព្រៃកោងកាង ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ឈ្មោះទីតាំង | ទំហំហត | ប្រភេទកូនឈើដែលត្រូវការពារ | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំចាប់ផ្ដើម | ថ្ងៃ/ខែ/ឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ដាំកូនព្រៃកោងកាង | ០២ | ព្រៃកោងកាង | ផ្សព្វផ្សាយ | ១៥/០៥/២០២២ | ៣០/០៥/២០២២ |
| | | | រៀបចំកូនឈើ | ១២/០៧/២០២២ | ០៧/០៧/២០២២ |
| | | | ពីធីដាំកូនឈើ | ១០/១០/២០២២ | ១១/១០/២០២២ |
| | | | ថែរក្សានិងការពារ | ២០២២ | ២០២៤ |
| ថែរក្សា និង ការការពារ ព្រៃកោងកាង | ៨០ | ព្រៃកោងកាង | • ផ្សព្វផ្សាយផែនការ<br>• ដាក់ស្លាកសញ្ញា<br>• ត្រួតពិនិត្យ | ២០២២ | ២០២៤ |

**គ.៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម**

ការចិញ្ចឹមត្រីជាទិសដៅដ៏សំខាន់របស់វិស័យជលផល ក្នុងការបង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងសម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារឱ្យមានការរីកចំរើន។ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចេញប្រកាសលេខ៣២៥ប្រក កសកស្តីពី ការគ្រប់គ្រងការចិញ្ចឹមត្រីរស់ ត្រីឆ្តោរដែលស្របនឹងតម្រូវការប្រជាពលរដ្ឋនៅមូលដ្ឋាន។ កន្លងមកសមាជិកសហគមន៍នេសាទកែបថ្មី ពុំអនុវត្តការចិញ្ចឹមត្រីសមុទ្រ និងទឹកសាបឡើយ។ ដូចនេះ ដើម្បីឆ្លើយតបនឹងត្រូវការសមាជិកសហគមន៍នេសាទកែបថ្មីមានផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រីឆ្តុង និងត្រីតក់កែ ក្នុងគោលបំណងដូចជា៖

- បង្កើនត្រីសាច់សម្រាប់ហូបចុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការ និងសមាជិកសហគមន៍នេសាទបាន រៀបចំផែនការអភិវឌ្ឍន៍ការចិញ្ចឹមត្រីដូចខាងក្រោម៖

| ប្រភេទវារីវប្បកម្ម | សកម្មភាព | ចំនួន | ប្រភេទកូនត្រី | បរិមាណកូនត្រី | ថ្ងៃ/ខែ/ឆ្នាំ | |
|---|---|---|---|---|---|---|
| | | | | | ចាប់ផ្តើម | ប្រមូលផល |
| ចិញ្ចឹមត្រីឆ្តុងតាមបច្ចេកទេសជាលក្ខណៈគ្រួសារក្នុងបែចំនួន៣០គ្រួសារ។ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើបែចិញ្ចឹម<br>• ផ្តល់កូនត្រី<br>• តាមដានត្រួតពិនិត្យ | ទំហំបែ=(៥មx៣មx២,៥ម)<br>**សរុប៣០បែ** | កូនត្រីឆ្តុង | ៥០០ក្បាល/គ្រួសារ | ២០២២ | ២០២៤ |
| ចិញ្ចឹមត្រីតក់កែតាមបច្ចេកទេសជាលក្ខណៈគ្រួសារចំនួន៣៥គ្រួសារ។ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើកន្លែងចិញ្ចឹម<br>• ផ្តល់កូន<br>• តាមដានត្រួតពិនិត្យ | ទំហំ១បែ=(៥ម x ៣មx២,៥ម)<br>**សរុប៣៥បែ** | កូនត្រីតក់កែ | ៥០០ក្បាល/គ្រួសារ | ២០២២ | ២០២៤ |
| ចិញ្ចឹមគ្រែងឈាមតាមបច្ចេកទេសជាលក្ខណៈសហគមន៍ | • ជ្រើសរើសសមាជិក<br>• បច្ចេកទេសចិញ្ចឹម<br>• ធ្វើកន្លែងចិញ្ចឹម<br>• ផ្តល់កូន<br>• តាមដានត្រួតពិនិត្យ | ១០ហិកតា | កូនគ្រែងឈាម | ១០០០គក | ២០២២ | ២០២៤ |

**គ.៧.ផែនការអភិវឌ្ឍន៍ផែនការអភិវឌ្ឍន៍ធនាគារក្តាមសេះ**

ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទកែបថ្មី ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទនៅក្នុងសហគមន៍ ជាពិសេស បានជួយកាត់បន្ថយសម្ពាធនៃការធ្វើអាជីវកម្មលើធនធានជលផលហួសកំរិត។ កន្លងមករដ្ឋបាលជលផល និងអង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេស ការចិញ្ចឹមសត្វ និងការចិញ្ចឹមត្រីលក្ខណៈគ្រួសារ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងៗដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារក្នុងគោលបំណង៖

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរ និងមានដើមទុនសំរាប់បង្កើនប្រាក់ចំណូល
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់ និងខ្ចីប្រាក់ពីឈ្មួញ
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង។

គណៈកម្មការសហគមន៍នេសាទកែបថ្មី មានផែនការអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិតសហគមន៍ដោយការបង្កើតធនាគារក្តាមសេះដែលចែកជា២៥ក្រុមតូចៗ ក្នុងនោះ១ក្រុមដែលមានចំនួន៥នាក់ដោយប្រើប្រាស់បច្ចេកទេសជាលក្ខណៈជាក្រុម។ ចំពោះបែចិញ្ចឹមត្រូវបានគ្រោងសាងសង់ជា២៥បែដែលក្នុង១បែមានទំហំ (៥មx៤មx២,៥ម)។

ផែនការអភិវឌ្ឍន៍មុខរបរចិញ្ចឹមជីវិតមានក្នុងតារាងខាងក្រោម៖

| ប្រភេទមុខរបរ | សកម្មភាព | ឯកតា | ថវិកា(រៀល) | ថ្ងៃ/ខែ/ឆ្នាំចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ធនាគារក្តាមសេះតាមបច្ចេកទេសជាលក្ខណៈជាក្រុម | ផ្សព្វផ្សាយទស្សនៈដល់សមាជិក | នាក់ | ១០០ ០០០ | ២០២២ | ២០២៤ |
| | បោះឆ្នោត និងរៀបចំក្រុម | ក្រុម | ៥០ ០០០ | | |
| | បង្កើតគោលការណ៍ | ច្បាប់ | ២០០ ០០០ | | |
| | បណ្តុះបណ្តាលដល់ក្រុម | វគ្គ | ៦០០ ០០០ | | |
| | សមាជិកក្រុមរៀបចំបែ | បែ | ៣ ០០០ ០០០ | | |
| | ផ្តល់ទុន(៣០០០០០៛/នាក់) | ប្រាក់ | ៧ ៥០០ ០០០ | | |
| | ត្រួតពិនិត្យតាមដានការអនុវត្តន៍ | ក្រុម | ១ ៥០០ ០០០ | | |

**គ.៨.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ**

ពេលបច្ចុប្បន្ន សហគមន៍នេសាទនេះបានគ្រោងផែនការរៀបចំកន្លែងកំសាន្តនៅកន្លែងមាត់សមុទ្រដែលជាដែននេសាទរបស់សហគមន៍នេសាទកែបថ្មី ដែលអាចជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ និងកាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯងសម្រាប់ក្នុងការចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព។ ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍កែបថ្មី ក្នុងគោលបំណងដូចជា៖

- បង្កើនប្រាក់ចំណូលដែលជួយស្តួយសេដ្ឋកិច្ចគ្រួសារ
- ជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង។

ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទមានដូចជា៖

| ប្រភេទមុខរបរ | សកម្មភាព | ឯកតា | ប្រភពថវិកា | ថ្ងៃ/ខែ/ឆ្នាំចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| រៀបចំកន្លែងកំសាន្តសម្រាប់សហគមន៍នេសាទកែបថ្មី | ផ្សព្វផ្សាយទស្សនៈដល់សមាជិក | នាក់ | គាំទ្រដោយដៃគូរអភិវឌ្ឍនិងស.ន | ២០២២ | ២០២៤ |
| | ការរៀបចំក្រុមសម្រាប់អនុវត្ត | ក្រុម | | | |
| | បង្កើតគោលការណ៍ | ច្បាប់ | | | |
| | បណ្តុះបណ្តាលដល់ក្រុម | វគ្គ | | | |
| | កន្លែងចំអិននិងបែងចែកអាហារ | កន្លែង | | | |
| | រៀបចំកន្លែងអង្គុយតូចៗ | កញ្ចះ | | | |
| | កន្លែងលក់សំបុត្រ | កន្លែង | | | |
| | ការិយាល័យធ្វើការងារ | កន្លែង | | | |
| | ត្រួតពិនិត្យតាមដាន | លើក | | | |

### គ.៩.ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ជាទូទៅ បេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទត្រូវបានបញ្ជាក់ពីគុណភាព និងចំណេះដឹងដូចជា ចេះអាន សរសេរ អាកប្បកិរិយាសមរម្យដោយឯកភាពពីសមាជិកសហគមន៍នេសាទ ហើយការរៀបចំបោះឆ្នោតជ្រើសរើសជាគណៈកម្មការ ដោយបានប្រើនិតិវិធីស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទដែលបានអនុម័តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែង គណៈកម្មការសហគមន៍នេសាទនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយត្រឹមត្រូវនិងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយញឹកញាប់សមាសភាពគណៈកម្មការសហគមន៍នេសាទគឺ ថ្មីដែលសមត្ថភាពរបស់សមាជិកគណៈកម្មការមានកំរិតលើការយល់ដឹងពីលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង ជំនាញសម្របសម្រួលទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងការៀបផែនការគ្រប់គ្រងកន្លែងសហគមន៍នេសាទ។ ដូចនេះ គោលបំណងនៃការបណ្តុះបណ្តាលគឺ

- គណៈកម្មការសហគមន៍នេសាទនឹងអាចអនុវត្តសកម្មភាពក្នុងការងារ
- យល់ពីតួនាទី និងភារកិច្ចរបស់ពួកគាត់
- បង្កើនសាមគ្គីភាព និងការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ។

ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| លរ | សកម្មភាព | ចំនួន | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ១ | បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិត រដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | ១លើក | ២០២២ | ២០២២ |
| ២ | បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ១លើក | ២០២២ | ២០២២ |
| ៣ | បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក | ២០២៣ | ២០២៣ |
| ៤ | បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ១លើក | ២០២៣ | ២០២៣ |
| ៥ | បណ្តុះបណ្តាលការរៀបចំផែនការ | ១លើក | ២០២៤ | ២០២៤ |

### គ.១០.ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ

ពេលបច្ចុប្បន្ន ធនធានជលផលក្នុងសហគមន៍នេសាទកែបថ្មីកំពុងទទួលរងនូវការគំរាមកំហែងពីអ្នកខាងក្នុងនិងខាងក្រៅ ដោយការកាប់រានព្រៃកោងកាង និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ ដូចនេះ ដើម្បីធានាការប្រើប្រាស់ធនធានជលផលពេលអនាគត និងបានយូរអង្វែងនោះ តម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឱ្យមានការយល់ដឹងគ្រប់គ្រាន់ក្នុងការចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តភាព ។ ការផ្សព្វផ្សាយច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណងដូចជា៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍

ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ ត្រូវបានរៀបចំដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | សកម្មភាព | អ្នកទទួលខុសត្រូវ | រយៈពេលអនុវត្ត ២០២២-២០២៤ | | | តម្លៃប៉ាន់ស្មាន (គិតជារៀល) | ប្រភពទុន |
|---|---|---|---|---|---|---|---|
| | | | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | | |
| ១ | ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | រដ្ឋបាលជលផល | ៤ | ៤ | ៤ | ១ ៥០០ ០០០ | រដ្ឋបាលជលផល ដៃគូអភិវឌ្ឍន៍ ក្រុមប្រឹក្សាសង្កាត់ |
| ២ | ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | គណៈកម្មការសហគមន៍ | ៤ | ៤ | ៤ | ១ ០០០ ០០០ | រដ្ឋបាលជលផល ដៃគូអភិវឌ្ឍន៍ សង្កាត់ |

**គ.១១.ផែនការបំពាក់សម្ភារៈការិយាល័យសហគមន៍នេសាទ**

ពេលបច្ចុប្បន្ន សហគមន៍នេសាទកែបថ្មីទើបបង្កើតស្នាក់ការសហគមន៍នេសាទដោយថវិកាសហគមន៍ផ្ទាល់តែនៅខ្វះថវិកាសម្រាប់បំពាក់សម្ភារៈក្នុងស្នាក់ការនេះ។ ដូចនេះ គណៈកម្មការខិតខំស្វែងរកថវិកា ដើម្បីបំពាក់សម្ភារៈសម្រាប់បំពេញការងារជារៀងរាល់ថ្ងៃដូចជា៖ ការងារទំនាក់ទំនងជាមួយក្រុមការងារផ្សេងៗ ឬភ្ញៀវទេសចរណ៍ជាដើម។ ដូច្នេះ ផែនការបំពាក់សម្ភារៈមួយចំនួនដូចជា តុសម្រាប់ធ្វើការងារ កៅអី ផែនទីសហគមន៍នេសាទ តុសម្រាប់ប្រជុំ និងទូឯកសារមានដូចខាងក្រោម៖

| សកម្មភាព | ទីតាំងគម្រោង | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ | តម្លៃប៉ាន់ស្មាន (រៀល) | ប្រភពទុន |
|---|---|---|---|---|---|
| គម្រោងបំពាក់សម្ភារៈស្នាក់ការស.ន | ស.ន | ២០២២ | ២០២៤ | ៥ ០០០ ០០០ | អង្គការដៃគូ សប្បុរសជន |

**គ.១២.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍នេសាទ**

ដោយឡែក គណៈកម្មការសហគមន៍នេសាទកែបថ្មី ត្រូវដើរតួនាទីសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលពីប្រភពផ្សេងៗដូចជា ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន ក្រុមប្រឹក្សាឃុំ-សង្កាត់ និងការធ្វើទស្សនៈកិច្ចរបស់ភ្ញៀវមកក្នុងសហគមន៍នេសាទ។ ផែនការស្វែងរកថវិកាមានដូចខាងក្រោម៖

| ល.រ | ប្រភេទចំណូល | សកម្មភាព | ថ្ងៃ/ខែ/ឆ្នាំ ចាប់ផ្តើម | ថ្ងៃ/ខែ/ឆ្នាំ បញ្ចប់ | ចំណូល (រៀល) |
|---|---|---|---|---|---|
| ១ | ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ផ្សព្វផ្សាយ និងបណ្ណភាគទាន | ២០២២ | ២០២៤ | ១ ០០០ ០០០ |
| ២ | ពីអ្នកនេសាទខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ចេញបណ្ណភាគទាន | ២០២២ | ២០២៤ | ១ ៥០០ ០០០ |
| ៣ | សប្បុរសជន និងអង្គការដៃគូអភិវឌ្ឍន៍ | • បង្កើតមុតរបរ<br>• ជាថវិកាផ្ទាល់ | ២០២២ | ២០២៤ | ៣ ៥០០ ០០០ |
| ៤ | ក្រុមប្រឹក្សាសង្កាត់ | ធនធានធម្មជាតិ | ២០២២ | ២០២៤ | ១ ៥០០ ០០០ |

### ឃ.យុទ្ធសាស្ត្រ

នៅក្នុងសហគមន៍នេសាទកែបថ្មី ត្រូវរៀបចំយុទ្ធសាស្ត្រមួយចំនួន ដើម្បីឱ្យការអនុវត្តផែនការទទួលបានជោគជ័យ។ យុទ្ធសាស្ត្រទាំងមានដូចខាងក្រោម៖

- គណៈកម្មការត្រូវធ្វើការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការរួមមាន៖ សមាជិកសហ-គមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍ និងចំណេះដឹងល្អជាពិសេសអំពីបញ្ហានេសាទ។
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់លើផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា៖ ការធ្វើផែនការកន្លែងអភិរក្សត្រីមេពូជ ការរៀបចំកន្លែងអភិរក្សព្រៃកោងកាង កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយ ដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់។
- ទាក់ទងជាមួយរដ្ឋបាលជលផល ដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ។
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍។
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ។
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ។
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កែបថ្មីរយៈពេល០៣ឆ្នាំ (ខែកុម្ភៈ ឆ្នាំ២០២២- ខែធ្នូ ឆ្នាំ២០២៤)

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ(រៀល) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ |
|---|---|---|---|---|---|
| **១.ផែនការប្រើប្រាស់ឧបណ៍នេសាទ** | •កាត់បន្ថយទំនាស់នេសាទក្នុងកន្លែងនេសាទ<br>•កាត់បន្ថយការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់<br>•សហគមន៍នឹងអនុវត្តន៍ប្រកាសស្តីពីការប្រើប្រាស់ឧបករណ៍ | **១ ៨០០ ០០០** | | ២០២២ | ២០២៤ |
| ១.១.ប្រជុំផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារក្នុង១ឆ្នាំ/៤ដង | សមាជិកនឹងយល់ដឹងពីការការប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារ | ១ ៨០០ ០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | | |
| ១.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ព័ន្ធនឹងចូលរួមផ្សព្វផ្សាយបន្តដល់សហគមន៍ | | | | |
| ១.៣.ត្រួតពិនិត្យនិងតាមដាន | គណៈកម្មការ និងសមាជិកចូលរួមឃ្លាំមើល និងរាយការណ៍ | | | | |
| **២.ផែនការចុះល្បាត** | •ទប់ស្កាត់ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់<br>•សមាជិកអាចទទួលបានផលនេសាទពីកន្លែងនេសាទសហគមន៍<br>•គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព | **១៤ ០០០ ០០០** | | ២០២២ | ២០២៤ |
| ២.១.ប្រជុំពិភាក្សាលើការរៀបចំផែនការល្បាត | ផែនការល្បាតបានពិគ្រោះយោបល់ និងរៀបចំសម្រាប់អនុវត្ត | ៥០០ ០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ២.២.រៀបចំមធ្យោបាយ និងសម្ភារៈ | មធ្យោបាយ និងសម្ភារៈបានគ្រោង និងរៀបចំ | ៩ ០០០ ០០ | | | |
| ២.៣.ប្រជុំផ្សព្វផ្សាយផែនការល្បាតដល់អ្នកពាក់ព័ន្ធ | ផែនការល្បាតត្រូវបានផ្សព្វផ្សាយ | ៥០០ ០០០ | | | |
| ២.៤.អនុវត្តផែនការចុះល្បាត | ផែនការចុះល្បាតត្រូវបានចុះអនុវត្ត | ៤ ០០០ ០០០ | | | |
| **៣.ផែនការកែលំអដែននេសាទ** | •បង្កើនផលត្រី វារីសត្វគ្រប់ប្រភេទ និងព្រៃកោងកាង<br>•ជួយថែរក្សាលំនឹងបរិស្ថានធម្មជាតិ<br>•មានភ្ញៀវទេសចរណ៍ និងផ្តល់ការងារដល់សហគមន៍<br>•សហគមន៍មានដើមទុនសម្រាប់ខ្លួនឯង | **១៦ ២០០ ០០០** | | ២០២២ | ២០២៤ |
| ៣.១.ផ្សព្វផ្សាយដល់អ្នកពាកព័ន្ធទាំងអស់ | អ្នកពាកព័ន្ធត្រូវបានផ្សព្វផ្សាយពីផែនការស្តារព្រែក | ២០០ ០០០ | អង្គការដៃគូ សប្បុរសជន រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៣.២.សិក្សាពីព្រែកអាវតាប៊ូ | ព្រែកអាវតាប៊ូត្រូវបានសិក្សា | ១ ០០០ ០០០ | | | |
| ៣.៣.ស្តារព្រែកអាវតាប៊ូដែលមានប្រវែង ១០០០មx៣០ម | ព្រែកអាវតាប៊ូប្រវែង១០០០មx៣០ម នឹងត្រូវបានស្តារ | ១៥ ០០០ ០០០ | | | |
| **៤.ផែនការរៀបចំកន្លែងអភិរក្ស** | •ប្រភេទត្រីមេពូជ និងវារីសត្វគ្រប់ប្រភេទត្រូវបានធ្វើការអភិរក្ស<br>•ប្រភេទព្រៃកោងកាងនឹងត្រូវបានការពារ | **១០ ៤០០ ០០០** | | | |

| | | | | | |
|---|---|---|---|---|---|
| | •ប្រជាជននឹងយល់ដឹងពីសារៈសំខាន់កន្លែងអភិរក្សនឹងចូលរួមថែរក្សា | | | | |
| ៤.២.ផ្សព្វផ្សាយដល់អ្នកពាក់ព័ន្ធ | អ្នកពាក់ព័ន្ធនឹងត្រូវបានផ្សព្វផ្សាយពីការបោះបង្គោល | ២០០ ០០០ | អង្គការដៃគូ<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៤.១.បោះបង្គោលស៊ីម៉ង់កន្លែងអភិរក្សអាវតាប៊ូ | បង្គោលចំនួន១៦ដើម នឹងបានបោះនៅកន្លែងអភិរក្សជាមួយផែនទីសំគាល់ | ៣ ០០០ ០០០ | | | |
| ៤.៣.ផលិតផ្ទាំងប៉ាណូផ្សព្វផ្សាយ | ចំនួន០២ស្លាកផ្ទាំងប៉ាណូនឹងបោះសម្រាប់ផ្សព្វផ្សាយ | ១ ២០០ ០០០ | | | |
| ៤.៤ សង់រោងយាម | រោងយាមចំនួន០១ត្រូវបានសាងសងនៅកន្លែងអភិរក្សទំហំ៤មx៥ម | ៥ ៨០០ ០០០ | | | |
| ៤.៥.ត្រួតពិនិត្យតាមដាន | ការរៀបចំកន្លែងអភិរក្សកនឹងត្រូវបានធ្វើការត្រួតពិនិត្យតាមដាន | ២០០ ០០០ | | | |
| **៥.ផែនការគ្រប់គ្រងព្រៃកោងកាងទំហំ៨០ហិកតា** | •សមាជិកសហគមន៍យល់ដឹងពីសារៈសំខាន់នៃព្រៃកោងកាង<br>•ព្រៃកោងកាងត្រូវបានការពារដោយសមាជិកសហគមន៍នេសាទ | **៤ ៦០០ ០០០** | | | |
| ៥.១.ប្រជុំផ្សព្វផ្សាយពីសារៈប្រយោជន៍ព្រៃកោងកាង | សមាជិកសហគមន៍យល់ដឹងពីសារៈប្រយោជន៍ព្រៃកោងកាង | ២០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ៥.២.រៀបចំថ្នាល និងការបណ្តុះកូនឈើ | ថ្នាលត្រូវបានរៀបចំនិងបណ្តុះកូនឈើ | ២០០ ០០០ | | | |
| ៥.៣.រៀបចំពិធីដាំកូនឈើលើផ្ទៃដីទំហំ០២ហិកតា | ពិធីដាំកូនឈើនឹងត្រូវបានប្រារព្ធឡើងលើផ្ទៃដីទំហំ០២ហិកតា | ១ ០០០ ០០០ | | | |
| ៥.៤.ធ្វើស្លាកសញ្ញាផ្សព្វផ្សាយការថែរក្សាព្រៃកោងកោង | ចំនួន០៤ស្លាកសញ្ញាត្រូវបានផលិត និងដាក់នៅទីតាំងព្រៃកោងកោង | ១ ២០០ ០០០ | | | |
| ៥.២.ការថែរក្សា និងការពារព្រៃកោងកាង៨០ហិកតា | អ្នកពាក់ព័ន្ធនឹងចូលរួមថែរក្សា និងការពារព្រៃកោងកាង៨០ហិកតា | ២ ០០០ ០០០ | | | |
| **៦.ការអភិវឌ្ឍន៍វារីវប្បកម្ម** | •បង្កើនត្រីសាច់សម្រាប់ហូបចុកក្នុងមូលដ្ឋាន<br>•រកប្រាក់ចំណូលជួយស្ថយសេដ្ឋកិច្ចគ្រួសារ<br>•កាត់បន្ថយសម្ពាធនេសាទលើធនធានជលផលហួសកំរិត | **៦ ០០០ ០០០** | | ២០២២ | ២០២៤ |
| **៦.១.ចិញ្ចឹមត្រីឆ្តុងតាមបច្ចេកទេស ជាលក្ខណៈគ្រួសារក្នុងបែចំនួន៣០គ្រួសារ** | | **២ ០០០ ០០០** | | | |
| ៦.១.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន៣០គ្រួសារត្រូវបានជ្រើសរើស | ២ ០០០ ០០០ | ដៃគូរអភិវឌ្ឍន៍<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៦.១.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឆ្តុង | ចំនួន៣០គ្រួសារ នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីឆ្តុង | | | | |
| ៦.១.៣.ធ្វើបែចិញ្ចឹមត្រីឆ្តុង | ចំនួន៣០បែដែលក្នុង១បែមានទំហំ៥មx៣មx២,៥មនឹងត្រូវបានសាងសង់ | | | | |
| ៦.១.៤.ការដាក់កូនត្រីក្នុងបែ | ចំនួនកូនត្រី៥០០ក្បាលនឹងត្រូវបានផ្តល់ក្នុងមួយគ្រួសារ | | | | |
| ៦.១.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន៣០គ្រួសារនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៦.២.ចិញ្ចឹមត្រីគក់កែតាមបច្ចេកទេស ជាលក្ខណៈគ្រួសារចំនួន៣៥គ្រួសារ** | | **៣ ០០០ ០០០** | | | |
| ៦.២.១.ជ្រើសរើសសមាជិកសហគមន៍ | សមាជិកសហគមន៍ចំនួន៣៥គ្រួសារត្រូវបានជ្រើសរើស | ៣ ០០០ ០០០ | ដៃគូរអភិវឌ្ឍន៍<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០២២ | ២០២៤ |
| ៦.២.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីគក់កែ | ចំនួន០៦គ្រួសារនឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រីគក់កែ | | | | |
| ៦.២.៣.ធ្វើបែចិញ្ចឹមត្រីគក់កែ | ចំនួន៣៥បែដែលក្នុង០១បែមានទំហំ៥មx៣មx២,៥មត្រូវបានសាងសង់ | | | | |
| ៦.២.៤.ការដាក់កូនត្រីក្នុងបែ | ចំនួនកូនត្រី៥០០ក្បាលនឹងត្រូវបានផ្តល់ក្នុងមួយគ្រួសារ | | | | |

| | | | | | |
|---|---|---|---|---|---|
| ៦.២.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ចំនួន០៦គ្រួសារនឹងត្រូវបានធ្វើការត្រួតពិនិត្យ | | | | |
| **៦.៣.ចិញ្ចឹមគ្រេងឈាមតាមបច្ចេកទេសជាលក្ខណៈសហគមន៍** | | **១ ០០០ ០០០** | | | |
| ៦.៣.១.ផ្សព្វផ្សាយដល់សមាជិកសហគមន៍ | សមាជិកសហគមន៍ស្ម័គ្រចិត្តត្រូវបានជ្រើសរើស | ១ ០០០ ០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២២ | ២០២៤ |
| ៦.៣.២.បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមគ្រេងឈាម | សមាជិកសហគមន៍នឹងត្រូវបានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម | | | | |
| ៦.៣.៣ រៀបចំកន្លែងចិញ្ចឹមគ្រេងឈាម | កន្លែងចិញ្ចឹមគ្រេងឈាមទំហំ១០ហិកតា ត្រូវបានរៀបចំ | | | | |
| ៦.៣.៤.ការដាក់កូនគ្រេងឈាម | កូនគ្រេងឈាមចំនួន១០០០គក នឹងត្រូវបានដាក់ក្នុងកន្លែងចិញ្ចឹម | | | | |
| ៦.៣.៥.ត្រួតពិនិត្យតាមដាន | សមាជិកសហគមន៍ធ្វើការត្រួតពិនិត្យការចិញ្ចឹមគ្រេងឈាម | | | | |
| **៧. ផែនការអភិវឌ្ឍន៍ធនាគារក្តាមសេះ** | •ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរ និងមានដើមទុនសំរាប់បង្កើនប្រាក់ចំណូល<br>•កាត់បន្ថយអត្រាការប្រាក់ខ្ពស់ និងខ្ចីប្រាក់ពីឈ្មួញ<br>•ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង | **១៥ ៥០០ ០០០** | | ២០២២ | ២០២៤ |
| ៧.១.ផ្សព្វផ្សាយទស្សនៈដល់សហគមន៍ | •អ្នកពាក់ព័ន្ធត្រូវផ្សព្វផ្សាយ | ៥០០ ០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២២ | ២០២៤ |
| ៧.២.ជ្រើសរើសក្រុមធនាគារក្តាមសេះ | ចំនួន០៥ក្រុមធនាគារក្តាមសេះត្រូវបានជ្រើសរើស(០៥នាក់/ក្រុម) | ៥០០ ០០០ | | | |
| ៧.៣.បោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន | ប្រធាន អនុប្រធានត្រូវបានជ្រើសរើសបោះឆ្នោត | ៥០ ០០០ | | | |
| ៧.៤.បង្កើតគោលការណ៍និងបទបញ្ជាផ្ទៃក្នុង | គោលការណ៍ និងបទបញ្ជាផ្ទៃក្នុងត្រូវបានបង្កើតឡើង | ៥០០ ០០០ | | | |
| ៧.៥.បណ្តុះបណ្តាលក្រុមពីឯកសារនិងថវិកា | សមាជិកធនាគារក្តាសេះត្រូវបានបណ្តុះបណ្តាល | ១ ៥០០ ០០០ | | | |
| ៧.៦.រៀបចំបែ | ចំនួន២៥បែត្រូវបានរៀបចំ( ទំហំបែ=៥ម x ៤មx ២,៥ម ) | ៦ ០០០ ០០០ | | | |
| ៧.៧.ផ្តល់ទុន | ទុននឹងត្រូវផ្តល់ដល់សមាជិកធនាគារក្តាមសេះម្នាក់ៗ | ៤ ៥០០ ០០០ | | | |
| ៧.៨.ត្រួតពិនិត្យតាមដានការអនុវត្តន៍ | ត្រួតពិនិត្យតាមដាននឹងត្រូវបានអនុវត្ត | ៥០០ ០០០ | | | |
| **៨.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ** | •បង្កើនប្រាក់ចំណូលដែលជួយស្តួយសេដ្ឋកិច្ចគ្រួសារ<br>•ជួយកាត់បន្ថយអត្រាចំណាកស្រុករបស់សមាជិកសហគមន៍នេសាទ<br>•កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត<br>•ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង | **២៧ ០០០ ០០០** | | | |
| ៨.១.ផ្សព្វផ្សាយទស្សនៈដល់សមាជិក | សមាជិកសហគមន៍ចំនួន១៤៧នាក់ ត្រូវបានផ្សព្វផ្សាយ | ៥០០ ០០០ | រដ្ឋាភិបាល អង្គការដៃគូ សប្បុរសជន | ២០២២ | ២០២៤ |
| ៨.២.ការរៀបចំក្រុមសម្រាប់អនុវត្ត | ចំនួន០១ក្រុមសម្រាប់កន្លែងកំសាន្តត្រូវបានបង្កើតឡើង | ៥០០ ០០០ | | | |
| ៨.៣.បង្កើតគោលការណ៍ និងបទបញ្ជាផ្ទៃក្នុង | គោលការណ៍ និងបទបញ្ជាផ្ទៃក្នុងត្រូវបានបង្កើតឡើង | ៥០០ ០០០ | | | |
| ៨.៤.បណ្តុះបណ្តាលពីការរៀបចំឯកសារ | ចំនួន០៥វគ្គ នឹងត្រូវបានរៀបចំ និងបណ្តុះបណ្តាល | ២ ៥០០ ០០០ | | | |
| ៨.៥.កន្លែងចំអិន និងរៀបចំអាហារ | កន្លែងចំអិនអាហារនឹងត្រូវបានរៀបចំ( ទំហំ=១០មx២០ម ) | ៥ ៥០០ ០០០ | | | |
| ៨.៦.រៀបចំកន្លែងអង្គុយតូចៗ(កញ្ចះ) | កញ្ចះអង្គុយនីមួយៗទំហំ( ៦មx៨ម )មានចំនួន២០កញ្ចះនឹងត្រូវបានរៀបចំ | ១០ ០០០ ០០០ | | | |

| | | | | | |
|---|---|---|---|---|---|
| ៨.៧.កន្លែងលក់សំបុត្រ | កន្លែងលក់សំបុត្រត្រូវបានរៀបចំ(ទំហំ=៥មx៨ម) | ២ ០០០ ០០០ | | | |
| ៨.៨.ការិយាល័យធ្វើការងារ | ការិយល័យចំនួន០១កន្លែងត្រូវបានបង្កើតឡើង(ទំហំ=១០មx២០ម) | ៤ ០០០ ០០០ | | | |
| ៨.៩.ត្រួតពិនិត្យតាមដាន | ការអនុវត្តការកន្លែងកំសាន្តរបស់សហគមន៍នេសាទត្រួតពិនិត្យនិងតាមដាន | ១ ៥០០ ០០០ | | | |
| **៩.ការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ** | •គណៈកម្មការនឹងអាចអនុវត្តសកម្មភាពក្នុងការងារ<br>•យល់ពីតួនាទី និងភារកិច្ចរបស់ពួកគាត់និង<br>•បង្កើនសាមគ្គីភាព និងការទំនាក់ទំនងល្អជាមួយអ្នកពាក់ព័ន្ធ | **១ ៧០០ ០០០** | | | |
| ៩.១.បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាល | កំណត់ហេតុ សរសេររបាយការណ៍ និងលិខិតរដ្ឋបាល នឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២២ |
| ៩.២.បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ការគ្រប់គ្រងថវិកានឹងត្រូវបានបណ្តុះបណ្តាល | ៣០០ ០០០ | | ២០២២ | ២០២២ |
| ៩.៣.បណ្តុះបណ្តាលការដោះស្រាយទំនាស់ | វិធីសាស្ត្រដោះស្រាយទំនាស់នឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២៣ | ២០២៣ |
| ៩.៤.បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ជំនាញសម្របសម្រួលនឹងត្រូវបានបណ្តុះបណ្តាល | ២០០ ០០០ | | ២០២៣ | ២០២៣ |
| ៩.៥.បណ្តុះបណ្តាលការរៀបចំផែនការ | ការរៀបចំផែនការ នឹងត្រូវបានបណ្តុះបណ្តាល | ៤០០ ០០០ | | ២០២៤ | ២០២៤ |
| **១០.ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ និងកសាងសមត្ថភាពគណៈកម្មការ** | • បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋ<br>• កាត់បន្ថយសកម្មភាពបទល្មើសនេសាទ | **២ ៥០០ ០០០** | | | |
| ១០.១.ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | សមាជិកសហគមន៍នឹងផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋាន | ១ ៥០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ១០.២.ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | សមាជិកសហគមន៍នឹងត្រូវបានផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង | ១ ០០០ ០០០ | | | |
| **១១.ផែនការបំពាក់សម្ភារៈស្នាក់ការសហគមន៍នេសាទ** | | **៥ ០០០ ០០០** | | | |
| ១១.១.ការបំពាក់សម្ភារៈ | សម្ភារៈកៅអី និងទូឯកសានឹងត្រូវបានបំពាក់ | ៥ ០០០ ០០០ | អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| **១២.ផែនការថវិកាសម្រាប់ទ្រទ្រង់សហគមន៍នេសាទ** | | **៦ ៥០០ ០០០** | | | |
| ១២.១.ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ភាគប្រចាំឆ្នាំពីសមាជិកសហគមន៍ | ១ ០០០ ០០០ | រដ្ឋាភិបាល<br>អង្គការដៃគូ<br>សប្បុរសជន | ២០២២ | ២០២៤ |
| ១២.២.ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ពីអ្នកនេសាទខាងក្រៅឬអ្នកមិនមែនជាសមាជិក | ១ ៥០០ ០០០ | | | |
| ១២.៣.អំណោយពីសប្បុរសជន និងអង្គការដៃគូ | សប្បុរសជន និងអង្គការដៃគូអភិវឌ្ឍន៍ | ៣ ៥០០ ០០០ | | | |
| ១២.៤.ក្រុមប្រឹក្សាសង្កាត់-ឃុំ | មូលនិធិរបស់សង្កាត់ | ១ ៥០០ ០០០ | | | |

# តារាងកម្មវិធីការងារសម្រាប់សហគមន៍នេសាទកែបថ្មីក្នុងរយៈពេល០៣ឆ្នាំ (ខែកុម្ភៈ ឆ្នាំ២០២២-ខែធ្នូ ឆ្នាំ២០២៤)

| សកម្មភាព | ២០២២ | | | | | | | | | | | ២០២៣ | | | | | | | | | | | | ២០២៤ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ខែនីមួយៗ | | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | | ខែនីមួយៗ | | | | | | | | | | | |
| | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| ១.ការប្រើប្រាស់ឧបករណ៍នេសាទក្នុងដែននេសាទសហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ២.ផែនការចុះល្បាត | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៣.ផែនការកែលំអដែននេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៤.ផែនការរៀបចំកន្លែងអភិរក្ស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៥.ផែនការគ្រប់គ្រងព្រៃកោងកាង | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៦.ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៧.ផែនការអភិវឌ្ឍន៍ធនាគារក្តាមសេះ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៨.ផែនការអភិវឌ្ឍន៍កន្លែងកំសាន្តរបស់សហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ៩.ផែនការពង្រឹងសមត្ថភាពគណៈកម្មការ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ១០.ផែនការផ្សព្វផ្សាយច្បាប់ជលផលនិងលិខិតបទដ្ឋានពាក់ព័ន្ធ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ១១.ផែនការបំពាក់សម្ភារៈការិយាល័យសហគមន៍នេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |
| ១២.ផែនការរកថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | → |

ទ្រ៤

សូមគោរពជូន

លោកមេឃុំបឹងទូក

ដើម្បីជូនពិនិត្យ និងសម្រួល

ថ្ងៃ[illegible] ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

..................ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០២១

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**កែបថ្មី**

ភឿន ណារ៉េង

លេខៈ ០១៥/២១ ម.ច

បានឃើញ និង គោរពជូន

លោកនាយសង្កាត់រដ្ឋបាលជលផល

ក្បាលរមាស

ដើម្បីជូនពិនិត្យ និងសម្រួល

ថ្ងៃ[illegible] ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ថ្ងៃទី.....០៧.....ខែ.....សីហា.....ឆ្នាំ២០២១

**មេឃុំ**

ឃឹម_វណ្ណា

បានឃើញ និង គោរពជូន

លោកនាយផ្នែករដ្ឋបាលជលផលព្រែកត្នោត

ដើម្បីជូនពិនិត្យ និងសម្រួល

ថ្ងៃ[illegible] ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ថ្ងៃទី...០៤...ខែ...សីហា...ឆ្នាំ២០២១

**នាយសង្កាត់រដ្ឋបាលជលផលក្បាលរមាស**

គី. ភារិន

បានឃើញ និង គោរពជូន

លោកនាយខណ្ឌរដ្ឋបាលជលផលកំពត

ដើម្បីជូនពិនិត្យ និងសម្រួល

ថ្ងៃ[illegible] ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ថ្ងៃទី...០៤...ខែ...សីហា...ឆ្នាំ២០២១

**នាយផ្នែករដ្ឋបាលជលផលព្រែកត្នោត**

អ៊ុន - ប៉ៅ

លេខៈ.....០៧៤២.....

បានឃើញ និង គោរពជូន

លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត

ដើម្បីជូនពិនិត្យ និងសម្រួល

ថ្ងៃ[illegible] ខែ[illegible] ទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

..........កំពត..........ថ្ងៃទី.....០៥.....ខែ.....សីហា.....ឆ្នាំ ២០២១

**នាយខណ្ឌរដ្ឋបាលជលផលកំពត**

ស សុរិន

លេខ.....៥៤០.....

បានឃើញ និង គោរពជូន

ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ

ថ្ងៃ[illegible] ខែ[illegible] ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

.....កំពត.....ថ្ងៃទី.....០៩.....ខែ.....សីហា.....ឆ្នាំ ២០២១

**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពត**

ចាន់ រិទ្ធិ

លេខ.....[illegible].....

បានឃើញ និងឯកភាព

ថ្ងៃ[illegible] ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី.....១១.....ខែ.....[illegible].....ឆ្នាំ២០២១

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

ពុំ សុថា